**ពេលប្រើបន្ថែមសម្រាប់ការស្នើសុំប្តូរពិន្ទុក្នុងឆ្នាំសិក្សា 2020-21**

ជម្រាបជូនមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស,

នៅខែកក្កដា 2021 មានច្បាប់រដ្ឋ កាលីហ្វ័រញ៉ា មួយហៅ AB 104 បានផ្តល់ឱកាសស្របតាមដំណើរការជាកម្រិតពេលសម្រាប់ការស្នើសុំប្តូរពិន្ទុជាអក្សរ ដែលសិស្សវិទ្យាល័យបានទទួលក្នុងឆ្នាំសិក្សា 2020-21 ឱ្យទៅជាពិន្ទុ Pass ឬ Not Pass (ជាប់ ឬ មិនជាប់) វិញបាន ។ ដំណើរការនេះប្រើជាផ្លូវការបានសម្រាប់តែសិស្សវិទ្យាល័យរៀនក្នុងឆ្នាំសិក្សា 2020-21 ប៉ុណ្ណោះ ហើយពេលសម្រាប់ប្រើមកលើការស្នើសុំប្តូរពិន្ទុ គឺត្រូវបានធ្វើបញ្ចប់នៅថ្ងៃទី15 ខែសីហា 2021 ។

ដោយមានមូលហេតុច្រើនជាប់ទាក់ទងគ្នា រាប់បញ្ចូលផងទាំងការប្រើពេល និង សេចក្តីប្រកាសខ្លីពេកកាលពីរដូវក្តៅ ដែលធ្វើឱ្យមាតាបិតាមានឱកាសតិចណាស់សម្រាប់ទទួលដំណឹង ក៏អ្នកបង្កើតច្បាប់បានរៀបចំទុកពេលប្រើបន្ថែមសម្រាប់ការស្នើសុំប្តូរពិន្ទុ ។ ច្បាប់ AB 167 ផ្តល់សិទ្ធិទៅកាន់ក្រសួងអប់រំ ឱស្រ្ទីគ ឱ្យធ្វើការទទួលជាបន្តអំពីការស្នើសុំប្តូរពិន្ទុពីសិស្សវិទ្យាល័យមកលើថ្នាក់ទាំងឡាយណាដែលពួកគេបានរៀនយកក្នុងឆ្នាំសិក្សា 2020-21 ។ ក្រសួងអប់រំ LBUSD កំពុងទទួលយកការស្នើសុំប្តូរពិន្ទុរហូតដល់ថ្ងៃទី15 ខែវិច្ឆិកា 2021 ។ មាតាបិតា និង សិស្ស គឺសុំជម្រុញឱ្យធ្វើការថ្លឹងថ្លែងមើលសិនអំពីវិជ្ជមាន និង អវិជ្ជមាន មុននឹងសម្រេចស្នើសុំប្តូរពិន្ទុ ។

**ច្បាប់អប់រំ**

*យោងតាមច្បាប់អប់រំ Education Code Section 49066.5 (2)(b): មាតាបិតា អ្នកគ្រប់គ្រង ឬ អ្នកមើលខុសត្រូវសិស្សស្របច្បាប់ខាងផ្នែកសិក្សា ឬ សម្រាប់សិស្សអាយុ 18 ឆ្នាំ ឬ លើសឡើងទៅ ... សិស្ស ដែលបានរៀននៅតាមវិទ្យាល័យ និង ចុះឈ្មោះរៀនយកថ្នាក់ក្នុងឆ្នាំសិក្សា 2020-21 គឺអាចបំពេញក្រដាសដាក់ពាក្យពីក្រសួងអប់រំ ឱស្រ្ទីគ របស់សិស្សបាន ដើម្បីស្នើសុំប្តូរពិន្ទុជាអក្សរ ដែលបានទទួលដូចតាមការរាយបង្ហាញនៅក្នុងសំណុំរឿងផ្នែកសិក្សារបស់សិស្ស ឱ្យទៅជាពិន្ទុ Pass ឬ No Pass វិញបាន ។*

**ដំណើរការសម្រាប់ស្នើសុំប្តូរពិន្ទុ**

ដើម្បីទទួលសិទ្ធិសម្រាប់ស្នើសុំប្តូរពិន្ទុបាន គឺសិស្សត្រូវតែមានការចុះឈ្មោះរៀននៅតាមវិទ្យាល័យក្នុងឆ្នាំសិក្សា 2020-21 ។

គ្មានការដាក់កម្រិតទេមកលើចំនួន ឬ ប្រភេទថ្នាក់ ដែលស្របតាមការបើកសិទ្ធិប្តូរពិន្ទុ ។ ប៉ុន្តែ សូមចំណាំថា ការស្នើសុំប្តូរពិន្ទុនៅតាមថ្នាក់រៀន ពីរ កន្លែង/រៀនស្របគ្នា ដែលបានបង្ហាត់ដោយគ្រូបង្រៀនផ្សេង ក្រៅពីក្រសួងអប់រំ ឱស្រ្ទីគ គឺត្រូវមានការជួបពិគ្រោះជាមួយវិជ្ជាស្ថាននោះសិន ដែលបានចែកផ្តល់ពិន្ទុទៅកាន់សិស្ស ។

ក្រដាសដាក់ពាក្យស្នើសុំប្តូរពិន្ទុនឹងត្រូវផ្ញើបញ្ជូនទៅកាន់ការិយាល័យ High School Office តាមរយៈ **Google Form** នេះ ឱ្យបានទាន់ថ្ងៃទី15 ខែវិច្ឆិកា 2021 ។ បើត្រូវការជំនួយស្វែងរកក្រដាសដាក់ពាក្យ ឬ ជំនួយបំពេញក្រដាសដាក់ពាក្យ គឺអ្នកអាចទាក់ទងទៅកាន់ការិយាល័យ High School Office បានតាមលេខទូរស័ព្ទ (562) 997-8115 ។

អ្វីមិនស្នើសុំប្តូរ មានន័យថា ពិន្ទុជាអក្សរ ដែលបានទទួលក្នុងឆ្នាំសិក្សា 2020-21 គឺនឹងនៅភ្ជាប់ជារហូតក្នុងសំណុំរឿងផ្នែកសិក្សារបស់សិស្ស ។

សំបុត្របញ្ជាក់នឹងផ្ញើជូន នៅពេលពិន្ទុរបស់សិស្សបានប្តូរផុតទៅ ក្នុងរយៈពេល 15 ថ្ងៃ ដែលបានទទួលក្រដាសដាក់ពាក្យស្នើសុំប្តូរពិន្ទុមកវិញ ។

**ព័ត៌មានដ៏សំខាន់ទាក់ទងឥទ្ធិពលនៃការប្តូរពិន្ទុសម្រាប់ចូលរៀននៅតាមមហាវិទ្យាល័យ**

ច្បាប់ចែងតម្រូវទៅកាន់ប្រព័ន្ធមហាវិទ្យាល័យ California State University ថា កុំឱ្យធ្វើការជំទាស់អំពីសិស្ស ដែលបានទទួលពិន្ទុ Pass/No Pass សម្រាប់ពេលសុំចូលរៀន ឱ្យតែអ្នកដាក់ពាក្យសុំចូលរៀនណាម្នាក់នោះបានរៀននៅតាមវិទ្យាល័យពិតមែនពីឆ្នាំសិក្សា 2020-21 រហូតដល់ឆ្នាំសិក្សា 2023-24 ។

**ការចែងតម្រូវនេះមិនអាចប្រើការបានទេទៅកាន់ University of California, មហាវិទ្យាល័យឯកជនក្នុងរដ្ឋ កាលីហ្វ័រញ៉ា និង មហាវិទ្យាល័យរដ្ឋ និង ឯកជនផ្សេងៗក្រៅរដ្ឋ កាលីហ្វ័រញ៉ា** ។ *ច្បាប់នេះសុំជម្រុញការគាំទ្រមែន ប៉ុន្តែ វាមិនអាចចែងតម្រូវបានទេសម្រាប់ឱ្យ University of California និង មហាវិទ្យាល័យឯកជននៅតាមកន្លែងផ្សេងៗ ធ្វើការទទួលស្គាល់មកលើពិន្ទុ Pass ឬ No Pass ។*

មានវិជ្ជាស្ថានឧត្តមសិក្សាជាច្រើនកន្លែងក្នុងរដ្ឋ កាលីហ្វ័រញ៉ា បានបង្ហាញថា គេនឹងមិនធ្វើការជំទាស់ទៅកាន់សិស្សទេ ដោយសិស្សនោះបានទទួលពិន្ទុ Pass/No Pass សម្រាប់សុំចូលរៀន ហើយបើចង់ដឹងច្បាស់អំពីឈ្មោះរាយបង្ហាញក្នុងបញ្ជី គឺអាចបើកមើលនៅតាម ... www.cde.ca.gov/ci/gs/ps/ab104surveyresults.asp ។

**សេចក្តីចំណាំ:** វិជ្ជាស្ថានឧត្តមសិក្សានៅតាមកន្លែងខ្លះ រាប់ទាំងនៅក្រៅរដ្ឋផង គឺប្រហែលជាមិនព្រមទទួលស្គាល់ទេមកលើពិន្ទុ Pass ឬ Not Pass ជំនួសពិន្ទុជាអក្សរ ដែលជាគោលដៅសម្រាប់សុំចូលរៀន ។ សម្រាប់សិស្សមានសំនួរ ដែលបានបំពេញក្រដាសដាក់ពាក្យ ឬ មានគោលបំណងបំពេញក្រដាសដាក់ពាក្យសម្រាប់រៀនជាមួយវិជ្ជាស្ថានឧត្តមសិក្សាណាមួយ ដែលគ្មានឈ្មោះរាយក្នុងបញ្ជីនៅតាមគេហទំព័រផ្នែកខាងលើនោះទេ គឺគេគួរត្រូវជួបពិគ្រោះជាមួយបុគ្គលិកប្រចាំការិយាល័យ Admissions នៅតាមកន្លែងនោះជាមុនសិន ។

អ្នកអាចទាក់ទងបានទៅកាន់ការិយាល័យ High School Office តាមលេខទូរស័ព្ទ (562) 997-8115 បើអ្នកមានសំនួរអំពីដំណើរការស្នើសុំប្តូរពិន្ទុជារបៀបនេះ ។